# ក្រុមជំនុំត្រូវបានបញ្ឆោតដោយលោកីយ៍

ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រារបស់ព្រះហើយបានផ្តល់ឱ្យយើងគ្រប់របស់ ទាំងអស់ ដោយឥតគិតថ្លៃនៅក្នុងព្រះគ្រីស្ទ។ យើងអរព្រះគុណជាខ្លាំង ព្រះអម្ចាស់ សម្រាប់ឯកសិទ្ធិដែលយើងបានទទួលដោយការលះបង់ដ៏អស្ចារ្យដែលព្រះយេស៊ូវបានប្រទានឱ្យយើងនៅកាល់វ៉ារី ដែលទ្រង់បានផ្សះផ្សាឱ្យយើងបានចូល ទៅក្នុង ការប្រកប និងការអនុគ្រោះដែលមាននៅក្នុងគម្ពីរបានសរសេរដូច្នេះថា "ប្រសិនបើអ្នករាល់គ្នាស្ថិតនៅជាប់នឹងពាក្យ**យើង**ហើយបើពាក្យ**យើង**ក្នុងអ្នក អ្នកអាច ប្រាថ្នានូវអ្វីដែលអ្នកចង់បានហើយទ្រង់នឹងប្រទានឱ្យអ្នកជាមិនខាន។" ឥឡូវ នេះយើងមានសេចក្តីអំណរចំពោះការអធិស្ឋានដែលទ្រង់នឹងផ្តល់ឱ្យយើងជឿលើទ្រង់ដោយអស់ពីចិត្តរបស់ពួកយើង។

2 ឥឡូវនេះសូមឱ្យយើងឈរនៅម្ខាងនៃព្រះអម្ចាស់គ្រប់កិច្ចការ គ្រប់ការ ថែរក្សាជីវិត ដូចជាអ្នកយាមម្នាក់ឬជាអ្នកគង្វាល ថាយើងមិនទាន់ យល់ពីអ្វីនៅក្នុងគំនិតរបស់ទ្រង់នៅពេលនេះទេ ប៉ុន្តែត្រូវរង់ចាំស្តាប់ដោយនូវព្រះ វិញ្ញាណ បរិសុទ្ធមានព្រះបន្ទូលមកកាន់យើង ដើម្បីយើងបានសម្រេចអ្វីដែលល្អ ដឹងកាន់ តែច្រើនពីទ្រង់ ដោយការជួបជុំគ្នា។ សម្រាប់ ព្រះជាម្ចាស់ នេះជាហេតុផលពិត ដែលយើងមកនៅក្រោមថ្ងៃដ៏ក្តៅនេះ។ សូមមានបន្ទូលមកកាន់យើងតាមរយៈ ព្រះបន្ទូលដ៏រស់ ហើយសូមឲ្យព្រះបន្ទូលដ៏រស់គង់ក្នុងយើង និងនៅជាប់ជាមួយយើង ដើម្បីឲ្យហើងបានស្រួចនិងរឹងមាំឡើង មិនមែនដោយលោកិយ៍ឡើយ ប៉ុន្តែត្រូវបានផ្លាស់ប្តូរដោយការកើតជាថ្មី សំរាប់វិញ្ញាណរបស់យើងឲ្យដូចទៅនឹងព្រះបុត្រានៃព្រះជាម្ចាស់។ អូចិត្ត របស់យើងភ័យញាប់ញ័រនៅពេលដែល យើងគិតដូចជាអំណរដ៏ជោរជន់ដល់ ព្រលឹងរបស់យើងដើម្បីដឹងថាយើងបានត្រលប់ជាកូនប្រុសស្រីនៃព្រះ។ យើងឈរ នៅលើសេចក្តីជំនឿរបស់ទ្រង់ដ៏មាំដរាបដល់ព្រះយាងមកផែនដីជាលើកទីពីរ និង ប្រជាជាតិ និងនគរទាំងប៉ុន្មានគឺនៅក្រោមព្រះបាទរបស់ទ្រង់ អ្វីទាំងអស់ពិភពលោកត្រូវបានបាត់បង់ ប៉ុន្តែនៅថ្ងៃមួយទ្រង់នឹងយាងមកយកយើងទៅកន្លែងដែលមានសេចក្តីសុខនៅក្នុងទ្រង់ ហើយមានជីវិតអស់កល្ប

ជានិច្ច និងមិនត្រូវបានផ្លាស់ប្តូរដែរ។ ហើយគិតថាឥឡូវនេះ—យើងជាផ្នែកមួយនៃ សាសន៍ស្អានស្អុត! ឱព្រះជាម្ចាស់អើយទ្រង់បានធ្វើពិធីកាត់ស្បែក ក្នុងចិត្តនិង ត្រចៀករបស់យើងនៅថ្ងៃនេះដោយ—ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយលាងដោយ ទឹកនៃព្រះបន្ទូល។ ដ្បិតយើងសូមនៅក្នុងព្រះនាមរបស់ទ្រង់និងសម្រាប់សិរីល្អ របស់ទ្រង់។ អាម៉ែន។

3 ខ្ញុំមានបំណងចង់លើកនូវប្រធានបទមួយនៅព្រឹកនេះ។ ដ្បិតខ្ញុំនឹង និយាយនៅលើអ្វីដែលខុសគ្នាបន្តិចបន្តួច ប្រសិនបើមានការអធិស្ថានប្រោសឱ្យជា ប៉ុន្តែយើងបានប្រកាសថាកាតអធិស្ឋាននឹងផ្តល់ឱ្យនៅម៉ោង ប្រាំបីរហូត ដល់ម៉ោងប្រាំបីសាមសិបឬម៉ោងប្រាំបួន។ហើយខ្ញុំគ្រាន់តែ...លោកប៊ីលលីឡើងមកនិយាយពីរឬបីនាទីមុនហើយគាត់បាននិយាយតែគ្មាននរណាម្នាក់ចង់ស្តាប់គាត់ទេនៅទីនេះដូច្នេះគាត់មិនបានឱ្យកាតអធិស្ឋានទេ។ ដូច្នេះយើងនឹង...ខ្ញុំបានគិតពីការទទួលយកអត្ថបទនេះសម្រាប់ជាការកែតម្រូវនៃក្រុមជំនុំ។ ហើយខ្ញុំចង់និយាយនៅលើប្រធានបទមួយ*លោកីយ៍នេះបានបញ្ឆោតក្រុមជំនុំ*។ ខ្ញុំចង់អានគម្ពីរមួយ ចំនួនពីគម្ពីរចៅហ្វាយជំពូកទី១៦ចាប់ផ្តើមជាមួយខទី១០។

*នោះដេលីឡានិយាយនឹងសាំសុនថា មើល បងបានបញ្ឆោតខ្ញុំ ដោយពោលសុទ្ធតែពាក្យភរភូតវិញ ម្តងនេះសូមប្រាប់ដល់ខ្ញុំ តើនឹងយកអ្វីមកចងបងឲ្យជាប់បាន។*

*គាត់ឆ្លើយថា បើគ្រាន់តែចងអញ ដោយពួរថ្មីដែលមិនទាន់ប្រើការសោះ នោះអញនឹងទៅជាខ្សោយ ដូចជាមនុស្សឯទៀតវិញ។*

*ដូច្នេះ ដេលីឡាក៏យកកថ្មីទៅចងរួចស្រែកថា សាំសុនអើយ នោះពួកភីលីស្ទីនមកចាប់បងហើយ ឯពួកអ្នកដែលបង្កប់ខ្លួន ក៏នៅចាំឮដ៏បន្ទប់ខាងក្នុង គាត់បណ្តាច់ពួរនោះចេញពីដៃទៅ គណនាដូចជាអំបោះ១សរសៃសុទ្ធ។*

*ដេលីឡានិយាយនឹងសាំសុនថា តាំងពីដើមដល់ឥឡូវនេះ បងនៅតែបញ្ឆោតខ្ញុំ ដោយនិយាយភូតភរដដែល ចូរប្រាប់មកខ្ញុំ តើត្រូវយកអ្វីចងបងឲ្យជាប់បាន គាត់ឆ្លើយថា ឲ្យឯងគ្រាន់តែក្រងសក់ក្បាលអញទាំង៧កំរងជាប់ជា១នឹងអំបោះអន្ទងទៅ។*

*នាងក៏បោះស្នៀតភ្ជាប់នឹងផ្សំថែមទៀត រួចស្រែកថា សាំសុនអើយ ន៏ ពួកភីលីស្ទីនមកចាប់បងហើយ នោះគាត់ភ្ញាក់ពីដេកឡើង ដោះស្នៀត ចេញពីកី ជាប់ទាំងអំបោះអន្ទងទៅផង។*

*នោះនាងនិយាយនឹងគាត់ថា ធ្វើដូចម្តេចឲ្យបងនិយាយថា បង ស្រឡាញ់ដល់ខ្ញុំបាន បើចិត្តបងទីទៃពីគ្នាដូច្នេះ បងបានបញ្ឆោតខ្ញុំ គ្រប់៣ដងនេះហើយ ឥតប្រាប់ពីដំណើរដែលបងមានកំឡាំងខ្លាំងទាំង ម៉្លេះពីណាកសោះ។*

*រួចមក ដោយនាងចេះតែរំអុកបង្ខំរាល់តែថ្ងៃ ដោយពាក្យសំដីនាង បានជាគាត់មានចិត្តព្រួយសឹងតែនឹងស្លាប់។*

*ហើយក៏បញ្ចេញប្រាប់អស់អំពីក្នុងចិត្តដល់នាងថា មិនដែលមាន កាំបិតកោរសក់ក្បាលអញឡើយ ដ្បិតអញជាពួកន៉ាសារីតដល់ព្រះ តាំងតែពីផ្ទៃម្តាយមក បើកោរសក់អញហើយ នោះកំឡាំងនឹងថយចេញ ពីអញទៅ ហើយអញនឹងទៅជាខ្សោយ ដូចជាមនុស្សឯទៀត។*

*កាលដេលីឡាឃើញថា គាត់បានបញ្ចេញប្រាប់អស់អំពីក្នុងចិត្ត ដូច្នោះ នោះនាងក៏ចាត់គេ ឲ្យទៅហៅពួកមេលើសាសន៍ភីលីស្ទីន មក ដោយពាក្យថា សូមឡើងមកតែម្តងនេះទៀតចុះ ដ្បិតវាបាន បញ្ចេញប្រាប់អស់អំពីក្នុងចិត្តដល់ខ្ញុំហើយ ដូច្នេះពួកមេក៏ឡើងមកឯ នាង ព្រមទាំងយកប្រាក់នោះមកផង។*

*ខណៈនោះនាងបានផ្តេកគាត់ឲ្យលក់នៅលើភ្លៅ រួចនាងហៅម្នាក់មក ឲ្យកោរកំរងទាំង៧ពីលើក្បាលគាត់ចេញ នោះនាងចាប់តាំងធ្វើទុក្ខដល់ គាត់ ហើយកំឡាំងក៏ថយចេញពីគាត់ទៅ។*

*រួចនាងស្រែកថា សាំសុនអើយ ន៏ ពួកភីលីស្ទីនមកចាប់បងហើយ*

*គាត់ក៏ភ្ញាក់ពីដេកឡើង នឹកថា អញនឹងចេញទៅរលាស់ខ្លួន ដូចជា សព្វ១ដង តែគាត់មិនដឹង ជាព្រះយេហូវ៉ាបានថយចេញពីខ្លួនទេ*

4 ឥឡូវនេះខ្ញុំចង់អានប្រធានបទមួយទៀតនៅគម្ពីរវិវរណៈជំពូកទី២ចាប់ផ្តើម ជាមួយនឹងខទី២១ដល់ខ២៣។

*ហើយអញបានឲ្យវាមានឱកាសនឹងប្រែចិត្ត ចេញពីការកំផិតរបស់វាដែរ តែវាមិនព្រម? សោះ*

*មើលអញនឹងបោះវាទៅលើគ្រែ ហើយបោះពួកអ្នក ដែលប្រព្រឹត្តសេចក្ដីកំផិតជាមួយនឹងវា ឲ្យទៅក្នុងសេចក្ដីវេទនាជាខ្លាំង លើកតែគេប្រែចិត្តលះបង់ការ ដែលគេប្រព្រឹត្តនោះចេញ។*

*ហើយអញនឹងសំឡាប់កូនចៅវាចោល នោះគ្រប់ទាំងពួកជំនុំនឹងដឹងថា គឺអញនេះហើយ ដែលស្ទង់មើលចិត្តនឹងថ្លើម រួចអញនឹងសងការដល់ឯងរាល់គ្នាតាមការដែលគ្រប់គ្នាបានប្រព្រឹត្ត។*

សូមឲ្យព្រះប្រទានពរដល់អស់អ្នកណាដែលបានអានព្រះបន្ទូលទ្រង់។

5 លោកសាំសុន គឺដូចជាព្រះវិហារដែរ ចាប់ផ្ដើមដើរមករកផ្លូវត្រូវ។ លោក
បានចាប់ផ្ដើមបែររកទិសដៅដ៏ត្រឹមត្រូវ។ លោកបានចាប់ផ្ដើម ធ្វើត្រឹមត្រូវហើយ
ត្រូវ បានគេហៅថាជាមនុស្សខ្លាំងពូកែអង់អាចម្នាក់។ លោកបានចាប់ផ្ដើមបម្រើ
ព្រះ អម្ចាស់និងធ្វើតាមបទបញ្ញត្តិ និងព្រះបន្ទូលរបស់ទ្រង់។ ហើយនោះគឺដូចជា
ក្រុមជំនុំរបស់ព្រះ។ គឺចាប់ផ្ដើមដូចដែលយើងអាចនិយាយថាជាលោកីយ៍និយាយ
ថាចាប់ផ្ដើមដើរផ្លូវត្រឹមត្រូវ។ ចាប់ផ្ដើមដើម្បីធ្វើតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់។
ហើយនៅពេលសាំសុនបានដើរតាមព្រះអម្ចាស់ ព្រះអម្ចាស់បានប្រើសាំសុន។

6 ដ្បិតព្រះទ្រង់អាចរក្សាទុកនរណា ម្នាក់និងប្រើប្រាស់នរណាម្នាក់ដែលនឹងមក
តាមព្រះអង្គព្រោះវាជាបំណងព្រះទ័យរបស់ព្រះ។ ប៉ុន្តែនៅពេល យើងនៅឆ្ងាយពី
ព្រះនោះព្រះជាម្ចាស់ទ្រង់មិនអាចប្រើយើងទៀតទេ។ នៅពេលដែលយើងសំឡឹង
ទៅមើលព្រះ និងព្រះទ័យរបស់ព្រះ នៅពេលដែលយើងនៅជាប់ នឹងព្រះ បន្ទូលនៃ
ព្រះ និងការគោរពបូជាដោយពាក្យសរសើរ និងថ្វាយបង្គំទ្រង់ដោយ ព្រះ វិញ្ញាណ
និងសេចក្ដីពិតបន្ទាប់មកព្រះអាចប្រើបុគ្គលណាមួយគ្រប់ពេល។ ប៉ុន្តែ នៅ ពេល
ដែលពួកគេយកទ្រឹស្ដីណាមួយដើម្បីងាកចេញពីព្រះនោះព្រះជាម្ចាស់មិនអាចប្រើ
មនុស្សម្នាក់នោះបានទៀតទេ។

7 ដូច្នេះ លោកសាំសុនគឺជាម្នាក់—ជាតំណាងដ៏ឆ្នើម ដែលបានលេចធ្លោរ យ៉ាង
ខ្លាំងនៃនរគព្រះសព្វថ្ងៃនេះ។ នៅពេលដែលនគរព្រះបានចាប់ផ្ដើមព្រះអាច ប្រើ
នរណាម្នាក់ក្នុងក្រុមជំនុំសម្រាប់បង្ហាញ ដល់ដៃអ្នកហើយដើរដោយឧស្សាហ៍

តាមបទបញ្ញត្តិរបស់ព្រះជាម្ចាស់រក្សាទុកការវិនិច្ឆ័យនិងច្បាប់ក្នុងការធ្វើអ្វីទាំងអស់ តាមព្រះទ័យរបស់ទ្រង់។ ហើយព្រះជាម្ចាស់គង់នៅជាមួយពួកជំនុំ។ ប៉ុន្តែវាហាក់ដូចជាមានកន្លែងចុះខ្សោយមួយក្នុងចំណោមក្រុមជំនុំទាំងអស់។

8 សូមចាំថា យើងមិនមែនដើរលេងកំសាន្តទេ ប៉ុន្តែយើងស្ថិតនៅក្នុងសមរភូមិ។ មនុស្សជាច្រើន គ្រាន់តែគិតថានៅពេល ដែលពួកគេបានក្លាយជាគ្រីស្ទានម្នាក់ នោះពួកគេទាំងអស់ត្រូវការធ្វើខ្លួន ដើម្បីក្លាយជាគ្រីស្ទជនដ៏ល្អម្នាក់ជារៀងរហូត នោះអ្វីគ្រប់យ៉ាងនឹងមកដោយងាយស្រួល។ កុំគិតវានៅក្នុងខួរក្បាលរបស់អ្នក។ សម្រាប់ ខ្ញុំបានក្លាយជាគ្រីស្ទានម្នាក់ដើម្បីប្រយុទ្ធប្រឆាំង ប្រយុទ្ធប្រឆាំងនឹងសេចក្តីជំនឿដើម្បីឱ្យបានរឹងមាំឡើង។ ខ្ញុំក្លាយទៅជាគ្រីស្ទាន ម្នាក់ដើរនៅ ក្នុងសមរភូមិ។ យើងជាទាហានគ្រីស្ទានយើងនឹងទទួលបានការបណ្តុះបណ្តាល និងបានដឹង ថាបច្ចេកទេសទាំងអស់របស់ខ្មាំងសត្រូវ និងដើម្បីដឹង ពីរបៀប ដើម្បី—ដើម្បី ប្រយុទ្ធប្រឆាំងនិងសត្រូវ។ ហើយយើងអាចធ្វើបានដូចដែល ព្រះវិញ្ញាណបរិសុទ្ធបង្ហាញវាដល់ពួកយើង។ យើងមិនអាចទទួលយក នូវអ្វីដែល ប្រទេស ជាតិមួយចំនួនផ្សេងទៀតបានប្រាប់យើងពីសង្គ្រាមខាងគំនិតរបស់ពួកគេទេ។ ប៉ុន្តែយើងទទួលយកគំនិតផ្ទាល់ខ្លួនរបស់យើង វិធីដែលព្រះវិញ្ញាណបរិសុទ្ធ នឹងដឹកនាំយើង ហើយអ្វី ដែលជាព្រះគម្ពីររបស់ព្រះនឹងផ្តល់ ឱ្យយើងដោយទ្រង់គឺ ជាមេដឹកនាំនៃកងទ័ពគ្រីស្ទាន។

9 សាំសុនបានធ្វើអំពើល្អ គាត់ជាមនុស្សអស្ចារ្យ (យើងចង់ហៅដូច្នេះ) ទ្រង់ នៅជុំវិញរហូតដល់គាត់បានទទួលទឹកដីរបស់ខ្លួនវិញ។ ហើយក្រុមជំនុំបានដំណើរការយ៉ាងស្រួល និងត្រឹមត្រូវរហូតដល់ពួកគេបានចាប់ផ្តើមដើម្បីទទួលបានទឹកដីរបស់ខ្លួនវិញ។ សាំសុនបានចាប់ផ្តើមដោយការស្រលាញ់។ ហើយគាត់មិន បានស្រលាញ់ក្មេងស្រីអ៊ីស្រាអែលទេ បែរជាស្រឡាញ់ស្ត្រីសាសន៍ ប៉ាលេស្ទីន។

10 ហើយនោះស្រដៀងទៅនឹងអ្វីដែលក្រុមជំនុំបានធ្វើ។ លោកមិនដែលចាប់ផ្តើម ស្រឡាញ់អ្វីដែលខ្លួនមានទេលោកចាប់ផ្តើមជាមួយអ្នកមិនជឿ។ នោះហើយ ជាកន្លែងដែលយើងបានធ្វើការ និងផ្នែកមួយនៃ កំហុសដ៏ធំគឺ នៅពេលដែលក្រុមជំនុំនេះបានចាប់ផ្តើមធ្វើអ្វីដែលមិនត្រឹមត្រូវ។ គឺដូចជាសាំសុន បានចាប់ ផ្តើមធ្វើអាក្រក់។

11 លោកសាំសុន ដរាបណាគាត់នៅជាមួយរាស្ត្ររបស់ព្រះគឺត្រឹមត្រូវណាស់។ ប៉ុន្តែនៅពេលដែលគាត់បានចែចង់ជាមួយមនុស្ស អាក្រក់បន្ទាប់មកឥឡូវគាត់កំពុងមានបញ្ហា។

12 ហើយនោះជាអ្វីដែលលោកបានធ្វើជាមួយនឹងក្រុមជំនុំ។ នៅពេលដែលក្រុមជំនុំគោរពជារៀងរាល់ថ្ងៃចំពោះការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ នោះព្រះប្រទានពរដល់ពួកគេ ការអស្ចារ្យនិងទីសំគាល់នឹងនៅជាប់ជាមួយក្រុមជំនុំ។ ប៉ុន្តែនៅពេលដែលវាចាប់ផ្ដើមការអាក្រក់ជាមួយនឹងពិភពលោក! ការអាក្រក់បំផុតបានសម្រេច ការដំបូងបានសម្រេច វាបានចាប់ផ្ដើមបំផ្លាញការប្រកប គ្នាជាមួយអ្នកជឿផ្សេងទៀត ដោយសារ តែពួកគេបានរកឃើញថាប្រទេសជាតិត្រូវបានរៀបចំ។ ប៉ុន្តែដំណឹងល្អ អស្ចារ្យនេះ មិនត្រូវបានឧទ្ទិសដល់ជាតិសាសន៍មួយ ឬមនុស្សណាម្នាក់ឡើយ។ គឺត្រូវឧទ្ទិសដល់ "អ្នកណាដែលចង់បាន ចូរឱ្យគាត់មក" គ្រប់ជាតិសាសន៍ទាំងអស់ គ្រប់ពូជពង្ស គ្រប់ភាសា និងគ្រប់មនុស្សទាំងអស់។ ព្រះទ្រង់មិនមានបំណងឲ្យយើងគូសនូវខ្សែបន្ទាត់ព្រំដែនឡើយ។

13 ប៉ុន្តែមនុស្សចង់ធ្វើដូចជា ពួកគេចង់ប្រៀបធៀប ឬចង់ថតចម្លង ដូចទៅនឹងអ្វីដែលលោកិយ—លោកិយបានធ្វើ និយាយដូចអ្វីដែលពួកគេបាននិយាយ ធ្វើជោគជ័យតាមវិធីដែលលោកកិយបានធ្វើ។ យើង មិនអាចទទួលបានជោគជ័យនូវអ្វីដែលលោកិយបានធ្វើនោះទេ។ យើង អាច ទទួលបានជោគជ័យលុះត្រាយើងបានធ្វើតាមព្រះទ័យរបស់ព្រះនិងវិធីរបស់ទ្រង់។ យើងមិនអាចមានជោគជ័យដោយសារគំរូរបស់លោកិយទេ។ ប្រសិនបើក្រុមហ៊ុនបារី បាន ទទួល ជោគជ័យធំបំផុតដោយសារទូរទស្សន៍ ហើយស្រាបៀរនិងស្រាវីស្គី ហ្វូងមនុស្សបានធ្វើឱ្យទទួលបានជោគជ័យ តាមរយៈការចូលរួមចំ ណែកនៃទូរទស្សន៍នោះ គ្មានទីសម្គាល់ណាដែលក្រុមជំនុំនឹងទទួលបានជោគជ័យតាមរយៈទូរទស្សន៍ឡើយ។ ភាពជោគជ័យនៃក្រុមជំនុំស្ថិតនៅក្នុងការ ផ្សាយដំណឹងល្អនៃអំណាចនៃព្រះហើយនឹងព្រះវិញ្ញាណបរិសុទ្ធ។ យើងមិនអាច និយាយថា ពីព្រោះតែទូរទស្សន៍បានធ្វើបែបនេះ—និង—បែបនេះ សម្រាប់ក្រុមហ៊ុនបារី និង—និងក្រុមហ៊ុនផ្សេងទៀត! យើងមិនមានបទគម្ពីរណាមួយដើម្បីព្យាយាម ដើម្បីប្រៀបធៀបជាមួយនឹងពួកគេបានទេ។ ហើយនៅពេលដែលយើងធ្វើដូចនោះ យើងអាចនាំមនុស្សជាច្រើនចូលមក ប៉ុន្តែនោះមិនមែនជាអ្វីដែលព្រះបានចាត់ឱ្យ យើងធ្វើ

ដូច្នោះទេ។ យើងគិតថាដោយសារតែថាយើងមានពណ៌សម្បុរផ្សេងគ្នានៅ ទីខ្ពស់មានអង្គការមួយធំ គេគិតថាកន្លែងនោះជាការជោគជ័យមួយ។ យើងត្រូវបានស្លាប់ជារៀងរាល់ថ្ងៃ នៅលើសេចក្តីជំនឿរបស់យើងបើនិយាយខាងវិញ្ញាណ! ប្រសិនបើយើងឈរដប់លាននាក់នៅព្រឹកនេះហើយព្រះវិញ្ញាណបរិសុទ្ធមិនគង់ជាមួយពួកយើង យើង មានមនុស្ស១០នាក់មានព្រះវិញ្ញាណគង់នៅជាមួយប្រសើរជាង។ យើងមិន អាចប្រៀបធៀបជាមួយនឹងពិភពលោកបានទេ។

14 ហើយរឿងដំបូងនោះគឺក្រុមជំនុំនេះបានចាប់ផ្តើមរៀបចំខ្លួនឯង។ ក្រុម ជំនុំលើកដំបូងគឺជាកាតូលិកហើយបន្ទាប់មកលូធឺរៀន (Lutheran)។ នៅពេលដែលពួកគេបានរៀបចំក្នុងក្រុមជំនុំ កាតូលិកដើម្បីធ្វើឱ្យក្លាយជាក្រុមជំនុំមួយថ្ងៃមួយ មានគេស្រែកឡើងថា "ភីលីស្ទីនគឺនៅលើអ្នកហើយ សាំសុន" ហើយសាំសុន បានបំបែកខ្សែព្រំដែននៃព្រះវិហារកាតូលិក ហើយលោកម៉ាធីនលូធឺក៏បានចេញមកជាក្រុមជំនុំនេះ។

15 បន្ទាប់មកពួកគេបានចងក្រុមជំនុំនេះដោយខ្សែមួយផ្សេងទៀតដូច នាងដេលីឡាបានធ្វើ។ ហើយពួកគេបានចាប់ផ្តើម...ជំនួសព្រះដោយហៅមនុស្ស—មនុស្សម្នាក់ ដោយព្រះវិញ្ញាណបរិសុទ្ធ ប្រហែលជាមិនស្គាល់(ABC)របស់ពួកគេ ប៉ុន្តែពួកគេបានស្គាល់ថាជាព្រះគ្រីស្ទ។ បន្ទាប់មកព្រះវិហារទទួលបានភាពទាន់សម័យហើយជាសម័យនយោបាយនេះ។ ហើយពួកគេឱ្យអ្នកអធិប្បាយរបស់ពួកគេនូវ "សញ្ញាប័ត្របណ្ឌិត" អ្នករាល់គ្នាបានក្លាយទៅជា បណ្ឌិតទេវសាស្ត្រ។ នោះគឺជាខ្សែមួយផ្សេងទៀតដើម្បីចងក្រុមជំនុំ។ មនុស្សត្រូវចូលទៅសិក្សាថ្នាក់រៀនជាន់ខ្ពស់របស់គាត់ ព្យាយាមធ្វើឱ្យល្អប្រសើរជាងមុនដូច្នេះក្រុមជំនុំរបស់ពួកគេអាចអួតថា "គ្រូគង្វាលរបស់យើងគឺ បណ្ឌិតផ្នែកទេវសាស្ត្រម្នាក់។" ហើយតើពួកគេបានធ្វើអ្វីខ្លះ?ម្នាក់ដែលព្យាយាមដើម្បីមានចំណេះដឹងកាន់តែច្រើនជាងម្នាក់ ផ្សេងទៀត។ បាទនោះមិនមានន័យថាអ្វីទាំងនោះនៅក្នុងបំណងព្រះទ័យរបស់ព្រះ ជាម្ចាស់ទេ។

16 ហើយទីនោះគ្មានការសម្រាប់បុរសណាម្នាក់ព្យាយាមទាញយកចំណេះដឹងខាងលោកីយ៍របស់គាត់នោះទេនិងមិនធ្លាប់គាប់ព្រះទ័យព្រះជាម្ចាស់ដែរ។ វាជាទីស្អប់ខ្ពើមបំផុតនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់! អ្នក មិនអាចផ្គាប់ព្រះទ័យ

ព្រះជាម្ចាស់ដោយមហិច្ឆតា និងចំណេះដឹងខាងលោកីយ៍ឡើយដោយសារតែ "វា ស្អប់ព្រះ" ព្រះបន្ទូលបានថែង។ គេមិនអាចធ្វើបែបនោះបានទេ។

17 ហើយម្នាក់ៗព្យាយាមចង់បានចំណេះដឹងទាំងអស់។ ពួកគេដឹងថាគ្រាន់តែធ្វើការអ្វីដែលត្រូវធ្វើ និងពាក្យក្នុងការនិយាយ ហើយវាបានក្លាយទៅជាភាសាអ្នក នយោបាយជំនួសឲ្យការបង្ហាញពីព្រះ រាជសារព្រះវិញ្ញាណបរិសុទ្ធបានជ្រាបដល់ដួងចិត្តរបស់មនុស្សម្នាក់ៗហើយបានរកឃើញអំពើបាបរបស់គាត់។ ពួកគេត្រូវបានហ្វឹកហ្វឺនសម្រាប់ការចរចានយោបាយមួយតែយើងមិនត្រូវការ។ ប៉ុលបាននិយាយថា "ពាក្យនេះមកដល់ពួកយើងមិនត្រឹមតែ...ឬ ដំណឹងល្អនៅក្នុងព្រះបន្ទូលតែប៉ុណ្ណោះទេប៉ុន្តែតាមរយៈអំណាចនិងការបង្ហាញនៃព្រះវិញ្ញាណ បរិសុទ្ធ។" ដែល បាននាំដំណឹងល្អបង្ហាញពីអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ! ប៉ុន្តែមនុស្សទាំង អស់នេះចូលទៅថ្នាក់សិក្ខាសាលា និងថ្នាក់ពួកគេរៀនការអប់រំល្អ របៀបដែល ពួក គេឈរនៅមុខមនុស្សរបៀបដែលពួកគេត្រូវតែធ្វើបទបង្ហាញដោយខ្លួនឯង របៀប ដែលពួកគេត្រូវតែស្លៀកពាក់ និងរបៀបដែលពួកគេត្រូវតែធ្វើសកម្មភាពពួក គេមិន គួរប្រើខុសវេយ្យាករណ៍ទេ។ ឥឡូវនេះជាការត្រឹមត្រូវទាំងអស់សម្រាប់សុន្ទរកថា មួយប៉ុន្តែយើងមិនបានយល់ពីអំពើអាក្រក់របស់មនុស្សបានធ្វើទេ។ លោកប៉ុល បាន និយាយថា "ដំណឹងល្អដែលខ្ញុំបានផ្សាយមិនបានមកដូចនោះទេ ប៉ុន្តែវាបាន មក តាមរយៈការរំឭក—រំឭកជាថ្មីនៃព្រះវិញ្ញាណបរិសុទ្ធនិង អំណាចនៃ ការបើក សម្តែង។" វាមិនបានមកដោយការបញ្ចេញសម្លេងត្រូវនោះទេនោះជាប្រាជ្ញារបស់ អ្នក នឹងត្រូវឬការជឿទុកចិត្តរបស់អ្នកនឹងមាននៅក្នុងប្រាជ្ញារបស់ មនុស្ស។ ប៉ុន្តែវាបានមកតាមរយៈការបើកបង្ហាញនៃអំណាចរបស់ព្រះគ្រីស្ទដែលរស់ឡើង វិញ។ នោះហើយជាដំណឹងល្អ "ដើម្បីដឹងថាទ្រង់ គឺជាអំណាចនៃការរស់ឡើងវិញរបស់ទ្រង់។"

18 មនុស្សម្នាក់ៗព្យាយាមគិតថា គាត់ជាម្នាក់ដែល ឆ្លាតជាងអ្នកដ៏ទៃទៀតគ្រាន់បើជាងនិកាយផ្សេងទៀតបន្តិច។ មេតូឌីសនឹងនិយាយថា "យើងបានទទួលបុរសម្នាក់ដែលឆ្លាតបំផុត។" បាប់ទីស្ទបាននិយាយ ហើយក្រុមជំនុំរបស់ព្រះគ្រីស្ទពួកគេទាំងអស់ថា"យើង យើងឆ្លាតបំផុត។ យើងប្រជាជនរបស់យើង—ប្រជាជនរបស់យើង យើងមិនអនុញ្ញាតឱ្យមនុស្សធម្មតាចេញទៅក្រៅនិងផ្សព្វផ្សាយដំណឹងល្អទេ។" ប៉ុន្តែពួកគេជ្រើសរើសដោយដៃ។ (ឱព្រះជាម្ចាស់អើយសូមអាណិតមេ

ត្តា!) ជ្រើសរើសដោយដៃពួកគេ ប្រសិនបើពួកគេមិនមានក្នុងឯកសារជាមួយនឹងគោលលទ្ធិជាក់ លាក់របស់ពួកគេទេពួកគេត្រូវនៅក្នុងព្រះវិហារ។ ព្រះជាម្ចាស់មិនអាចប៉ះពួកគេ បានទេ វិធីណាក៏ដោយ។ ខ្ញុំចង់បាននរណាម្នាក់ដើម្បីផ្សាយដំណឹងល្អ ដែលបានជ្រើសរើស ដោយព្រះវិញ្ញាណបរិសុទ្ធ ព្រះបានលើកគេឡើង មិនមែនរើសដោយមនុស្សណាម្នាក់ឬនិកាយមួយណាឡើយ។

19 ចំណេះដឹងទាំងអស់! ពួកគេនិយាយថា "អូ! យើងបានដឹងទាំងអស់អំពីវា" ហើយពួកគេខ្លះមិនបានចេះព្យញ្ជនៈដំបូងនៃព្រះវិញ្ញាណ បរិសុទ្ធផង។ ពួកគេបានបដិសេធវា។

20 វារំឭកខ្ញុំពី សៀវភៅតូចមួយដែល ខ្ញុំបានអាននៅក្នុង រដ្ឋកាលីហ្វូនញ៉ា ប្រហែលដប់ឆ្នាំមុន។ ខ្ញុំជ្រើសរើសទិញវានៅក្នុងហាងលក់សៀវភៅចាស់មួយ។ ខ្ញុំភ្លេចឈ្មោះអ្នកនិពន្ធ។ វាគ្រាន់តែជាសៀវភៅតម្លៃដប់សេនប៉ុណ្ណោះទេប៉ុន្តែវាទាក់ទាញ អារម្មណ៍ណាស់ វាហាក់ដូចជាកំប្លែង និងបង្កើនប្រាជ្ញា។ ប៉ុន្តែខ្ញុំបានរកឃើញ នៅក្នុងសៀវភៅនោះដូចជាព្រះជាម្ចាស់ឱ្យខ្ញុំបានឮអ្វីមួយ។ ហើយរឿងមួយក្នុង ចំណោមរឿងរ៉ាវតូចនេះបានចាប់ផ្តើមដូច្នេះ។ នៅព្រឹកមួយនៅក្នុងទ្រុងមាន់មួយយ៉ាងធំមានមាន់តូចមួយក្នុងទ្រុងនោះ វាគិតថាវានឹងប្រើចំណេះដឹងទាំងអស់ ដើម្បីឱ្យគេស្គាល់។ ដូច្នេះវាបានហោះហើរឡើងនៅលើប្រអប់មួយ ហើយវាយ ធាក់ប្រអប់នោះបួនឬប្រាំដងដោយក្បាលរបស់វាហើយរងាវ ឡើងដូចជាយើងមិនដែលឮមាន់រងាវ។ ហើយម្យ៉ាងទៀត វាបានទាក់ទាញការយកចិត្តទុកដាក់របស់ពួកគេឱ្យមកមើលវាហើយវាបាននិយាយថា "អស់លោកលោកស្រីមាន់ដែលនៅក្នុងទ្រង់នេះខ្ញុំចង់និយាយទៅកាន់អ្នកទាំងអស់គ្នាព្រឹកនេះនៅលើកម្មវិធីអប់រំដ៏ អស្ចារ្យដែលយើងទើបតែបានរចនាវាឡើង។" និយាយថា "ខ្ញុំបានតម្រូវឱ្យមាន ចំណេះដឹងច្រើននៅក្នុងការសិក្សារបស់ខ្ញុំ" ខណៈនោះលោកទាញវ៉ែនតា លើសេចក្តីថ្លែងរបស់វា។ ហើយវាបាននិយាយថា "ខ្ញុំបានសម្រេចចិត្តថាគ្នាយើង មាន់ទាំងអស់អាចប្រសើរជាងនេះបើមានចំណេះដឹងបន្ថែមទៀត។ ដូច្នេះខ្ញុំអាចប្រាប់អ្នកកន្លែងដែលយើងនឹងជីកនិងធ្វើការនៅក្នុងទ្រុងនេះ ឬវន្ធមួយយើងនឹងរកឃើញវីតាមីនមួយដែលនឹងធ្វើឱ្យពោមស្អាតហើយឆាប់លូតលាស់ល្អប្រសើរជាងមុន។ អូ! ហើយខ្ញុំប្រាប់អ្នកពីរបៀប ដែលយើងអាចធ្វើខ្លួនយើងបានល្អប្រសើរជាងមុននៅក្នុងវិធីផ្សេងគ្នាជាច្រើន។"

21 ហើយមានមាន់ញីជំទង់ មានសេក្របាមតូចបានខ្ពតហើយបាននិយាយថា "តើគាត់គួរឲ្យស្រទ្បាញ់ដែរទេ?" ហើយពួកគេពិតជាកោតសរសើរគាត់។ "អូ! វាគឺ ដូចជាមាន់អស្ចារ្យ!" វាបានរំឮកខ្ញុំពីគ្រូអធិប្បាយ មួយចំនួននៃថ្នាក់សិក្សានៅទីនេះ។ "បែបជាបុរសអស្ចារ្យ! មិនចាំបាច់យើងជាមួយមាន់ដ៏ទៃទៀតទេ យើងទាំងអស់គ្នាគួរតែទៅជាមួយគាត់។"

22 ល្អណាស់ មុនពេលដែលមិត្តនោះ បញ្ចប់ការនិយាយរបស់គាត់ មានសត្វមាន់តូចមួយទៀត ដែលមិនមានរោមភ្លឺដូចគេទេនោះកំពុង រត់មកហើយនិយាយថា "ហេចាំបន្តិច! ខ្ញុំបានឮសេចក្តីប្រកាសចុងក្រោយបំផុតតាមវិទ្យុ។មាន់ដែលមានតំលៃមួនសេនក្នុងមួយផោននឹងត្រូវសម្លាប់នៅថ្ងៃស្អែក! តើចំនេះដឹងរបស់អ្នកមានប្រយោជន៍អ្វី?"

23 បងប្អូនអើយចំណេះដឹងដែលយើងមានច្រើនណាស់ តើមានប្រយោជន៍អ្វី? យើងមានកំពស់តែប្រាំមួយហ្វូតពីដី! យើងស្លាប់ដោយសារប្រវែងនិងពេលវេលា។ ចំណេះដឹងរបស់យើង គ្មានន័យអ្វី ទាំងអស់។ យើងទាំងអស់គ្នាចង់ស្គាល់ព្រះជាម្ចាស់។ ប៉ុន្តែពួក គេបែរជាធ្វើបែបនោះទៅវិញ។

24 ដូចពេលដែលខ្ញុំបានកត់ សំគាល់ពេលកន្លងទៅនេះ អំពីសត្វមាន់តូច មួយវាគិតថាវាមានចំណេះដឹងទាំងអស់ដែលត្រូវការហើយវាបានដឹង ច្រើនដូច្នេះ—ដូច្នេះវាអាចប្រាប់មាន់ទាំងអស់អំពីមនុស្ស។ ដូច្នេះវាបានហោះ ឡើងទៅលើទ្រុងរបស់វាហើយវាចាប់ផ្តើម ប្រាប់មាន់ទាំងអស់អំពីមនុស្សនិងរបៀបដែលវាស្គាល់ពីពួកគេ។ ហើយរំពេចនោះសាស្ត្រាចារ្យម្នាក់មកពីភើរឌូក៏ដើរឡើងមកនិងនិយាយពាក្យសំខាន់មួយចំនួនទៅកាន់វា ហើយមាន់តូចនោះបានងាកភ្នែកចេញបែរក្បាល របស់គាត់ចេញ...ឥឡូវនេះគាត់មានភ្នែកវាអាចមើលឃើញសាស្ត្រាចារ្យបាន។ វាមានត្រចៀកវាអាចលឺគាត់បាន។ ប៉ុន្តែពិតណាស់វាមិនអាច ដឹងថាគាត់កំពុងនិយាយ អំពីអ្វីនោះទេ។ ហេតុអ្វី?វាមានខួក្បាលជាកូនមាន់។ វាគ្រាន់តែជាខួរក្បាលបក្សីតូចមួយ។ នោះជាអ្វីដែលវាមាន។ វាមិន មានខួរ ក្បាលមនុស្សទេ ដូច្នេះវាមិនអាចគិតដូចមនុស្សបានទេ។

25 ហើយចុះតើមនុស្សអាចគិតដូចជាព្រះបានទេ! អ្នកជាមនុស្សចំណេះដឹងខាងលោកីយ៍ទាំងអស់មិនលើសជាងខួរក្បាលកូនមាន់ដែរ។ អ្វីទាំងអស់ ដែល អ្នកធ្វើ អ្នកគ្រាន់តែធ្វើឱ្យខ្លួនឯងឈឺចាប់ប៉ុណ្ណោះ។ អ្នកត្រូវមានគំនិតរបស់ព្រះគ្រីស្ទ។

26 មូលហេតុដែលមនុស្សចូលរួមក្នុងអង្គការជាច្រើន ហើយចាប់ដៃជំនួស ការកើតជាថ្មី ពួកគេកំពុងព្យាយាមដើរវាងការកើតជាថ្មី។ ពួកគេមិនចង់ កើតជាថ្មីទេ។ ហើយពួកគេដឹងថា—ដឹងថាយើងបង្រៀនគេនៅក្នុងព្រះគម្ពីរដូច្នេះ ពួកគេចង់ជំនួសអ្វីមួយប៉ុណ្ណោះ។ ហើយពួកពេនតេកុស្ត នេះគឺអាក្រក់ដូចជាការព្យាយាមរកអ្វីមួយដើម្បីជំនួស! ពួកគេចង់ឲ្យវាទាន់សម័យ។ វាត្រូវតែទាន់សម្ទួយ "យើងនឹងចាប់ដៃគ្នាហើយចូលរួមក្នុងក្រុមជំនុំ ហើយប្រោះទឹក ឬ ជ្រមុជទឹក" ឬអ្វីមួយផ្សេងទៀត។ ពួកគេ ភ័យខ្លាចចំពោះការកើតជាថ្មី។ ពេលខ្លះខ្ញុំជឿថារោងឧបោសថប្រាណហាក់ខ្លាចវាដែរ!

27 ឥឡូវនេះ យើងទាំងអស់គ្នាដឹងថាយើង មានកំណើតមួយខ្ញុំមិនខ្វល់ថាជាកន្លែងណាឬកន្លែងណាក៏ដោយគឺវារញ៉េរញ៉ៃ។ បើទារកកើតលើលើគំនរគជ្ជ ឬនៅលើការ៉ូឬក្នុងបន្ទប់មន្ទីរពេទ្យដ៏ស្អាតគឺរញ៉េរញ៉ៃ កន្លែងណាក៏ដោយ។ កំណើតកូនគោកំណើតរបស់អ្វីផ្សេងទៀតគឺមានភាពរញ៉េរញ៉ៃ។

28 ហើយការកើតជាថ្មីគឺគ្មានអ្វីក្រៅពីរញ៉េរញ៉ៃទេ!ប៉ុន្តែមនុស្សនៅតែជំនះ "យើងនឹងចូលទៅកន្លែងដែលពួកគេចាប់ដៃគ្នា។ យើងនឹងទៅកន្លែងដែលពួកគេមិនស្រែកនិងយំនិងការវាយអាសនៈហើយយំ។" អ្នកចង់ក្លាយជាមនុស្សល្អ! អ្វីដែលយើងត្រូវធ្វើគឺកើតជាថ្មីដែលនាំមកនូវជីវិតដ៏អស់កល្ប!

29 គ្រាប់ពូជ ដំឡូងអាយុចាស់ គ្រាប់ពូជដំឡូងមាន អ្នកយកដំឡូងនោះហើយដាំវានៅក្នុងដី។ រហូតដល់អ្នកទទួលបានដំឡូងថ្មី ដំឡូងចាស់នោះត្រូវតែរលួយ។ ពោតមិនអាចផលិតជីវិតថ្មីរហូតដល់វារលួយជាមុនសិន។

30 ហើយបុរសឬស្ត្រី មិនអាចមានកំណើតថ្មី រហូតដល់ប្រាជ្ញានិងខ្លួនពួកគេរលួយ ការស្លាប់ ស្លាប់នៅឯអាសនា ហើយស្រែក ទាំងអស់គឺរញ៉េរញ៉ៃចូរយកកន្លែងដែលរញ៉េរញ៉ៃចេញពីអ្នកហើយអ្នកត្រូវបានកើតជាថ្មីដោយព្រះវិញ្ញាណនៃព្រះ។ ខ្ញុំមិនខ្វល់ទេប្រសិនបើអ្នកនិយាយភាសាដទៃវានឹងឆាប់បាត់ទៅវិញលោតចុះឡើងៗ ដូចសត្វមាន់នឹងក្បាលរបស់វាស្មានតែបានជីវិតជាថ្មី! ប៉ុន្តែយើងជំនួសអ្វីមួយដើម្បីកើតជាថ្មី យើងត្រូវការការទាន់សម័យ ប្រាកដណាស់។

31 កាលពីថ្ងៃសុក្រប្រពន្ធខ្ញុំនិងខ្ញុំបានទៅហាងមួយ។ ខ្ញុំមិនបានមានន័យ ច្រំដែលៗទេ។ ប៉ុន្តែខណៈដែលយើងបានចុះទៅតាមផ្លូវមួយ ខ្ញុំបានងាកក្បាលរបស់ខ្ញុំគិតអំពីស្ត្រីអាក្រាតម្នាក់ផ្សេងទៀត។ ខ្ញុំបានសន្យាជាមួយព្រះនៅពេល

ដែល ខ្ញុំជាមនុស្សខ្វាក់ប្រសិនបើទ្រង់បានព្យាបាលភ្នែករបស់ខ្ញុំឱ្យជាសះស្បើយ ខ្ញុំចង់សម្លឹងមើលទៅរឿងដែលត្រឹមត្រូវ។ ហើយខ្ញុំបានព្យួរឈើឆ្កាងតូចមួយនៅក្នុងរថយន្តរបស់ខ្ញុំ។ ពេលដែលខ្ញុំឃើញការនោះ ខ្ញុំសម្លឹងទៅឈើឆ្កាងនោះ ហើយខ្ញុំនិយាយថា "ឱព្រះជាម្ចាស់អើយ! ទ្រង់ជាជម្រករបស់ខ្ញុំ" ដូចដែលខ្ញុំបានសម្លឹងទៅឈើឆ្កាង។

32 ខ្ញុំបានឃើញស្ត្រីទាំងនោះ។ មេដា(Meda)និយាយថា "យើងមិនដែលឃើញស្ត្រីណាម្នាក់ស្លៀកសំពត់ទេសព្វថ្ងៃនេះ។" ហើយនាងបាននិយាយថា"ប៊ីលមើលទៅស្ត្រីម្នាក់ដែលនៅទីនោះជាមួយកាបូបតូចដែល ស្ពាយជុំវិញរាងកាយរបស់នាង" ហើយនិយាយថា "អ្នកមានន័យថាអ្នកចង់ប្រាប់ ពីស្ត្រីម្នាក់ដែលមិនដឹងថាខ្លួននាងមានអ្វីខុសឬ?" ហើយបាននិយាយថា "ប្រសិន បើនាងមិនបានដឹងថាវាជាការខុសគឺនាងបានស្ថិតនៅក្រៅគំនិតត្រឹមត្រូវ។"

33 ខ្ញុំនិយាយថា "ចាំមួយភ្លែតបងសំលាញ់។ នាងជាជនជាតិអាមេរិកម្នាក់ នាងបានធ្វើអ្វីដូចជាជនជាតិអាមេរិកធ្វើដែរ។" ខ្ញុំបាននិយាយថា "កាលខ្ញុំនៅហ្វាំងឡង់មិនយូរប៉ុន្មានទេបង។"

34 ខ្ញុំបានសួរទៅបុរសម្នាក់នៅ ទីនោះដែលបានដាក់ខ្ញុំចុះ គឺវេជ្ជបណ្ឌិត ម៉ានីនិន។ ហើយយើងកំពុងតែទៅ—ងូតទឹកសុខភាពដែលហៅថា "សូណា" ហើយពួកគេយកអ្នកទៅក្នុងហើយចាក់ទឹកក្តៅលើខ្លួនឬ ចាក់លើថ្ម ហើយអ្នកនិង មានញើស។ បន្ទាប់មកវានិងធ្វើឲ្យអ្នកលោតចូលទៅក្នុងទឹកត្រជាក់ និងចេញមកវិញម្តងទៀត។ បន្ទាប់មកគេយកអ្នកចូលទៅក្នុងបន្ទប់មួយមាន គិលានុបដ្ឋាយិកាស្ត្រីជាអ្នកកោសជុបឲ្យបុរស (នៅខ្លួនទទេ)ហើយបញ្ជូនពួកគេចូលទៅក្នុងអាងហែលទឹកវិញ។ ខ្ញុំមិនចូលទៅក្នុងនោះទេ។ ខ្ញុំបាននិយាយថា "ដុកទ័រម៉ានីន អ្នកធ្វើនេះជាការខុសហើយ។"

35 គាត់បាននិយាយថា "មិនអីទេព្រឹទ្ធាចារ្យ ប្រាណហាំនោះជាការខុស។ បន្ទាប់មកចុះអំពីគ្រូពេទ្យជនជាតិអាមេរិករបស់អ្នកដែលនឹងឱ្យស្ត្រីស្រាត និងដាក់នាងនៅលើតុពិនិត្យមើលសរីរាង្គភេទ—ភេទរាល់សីរីរៈដែលនាងមាន? ចុះចំនែកគិលានុប្បដ្ឋានយិកាទាំងអស់នៅក្នុងមន្ទីរពេទ្យនេះយ៉ាងម៉េចដែរ?

36 ខ្ញុំនិយាយថា "សូមទោសបងប្រុសម៉ានីនអ្នកនិយាយត្រូវហើយ។"

37 តើវាជាអ្វី? គេជាប្រពៃណី។ នៅពេលដែលខ្ញុំនៅទីក្រុងប៉ារីសខ្ញុំស្ទើរតែមិនជឿ ថាបន្ទប់ទឹករបស់បុរសនិងស្ត្រីគឺនៅជាមួយគ្នា។ ខ្ញុំមិនអាចយល់វាបានទេថាបន្ទប់ទឹកតាមផ្លូវនេះសម្រាប់ទាំងបុរស និងស្ត្រី។ ខ្ញុំមិនជឿថាស្ត្រីបានទៅឆ្នេរដើម្បីទៅហែលទឹកជាមួយសង្សាររបស់គាត់ទេ ពួកគេមិនមានបន្ទប់សម្រាប់សម្លៀកបំពាក់ ទេពួកគេបានយកតែសម្លៀកបំពាក់មួយកំភ្លេរ តែប៉ុណ្ណោះបន្ទាប់មកពួកគេបាន ដាក់ខ្សែតូចនៅលើរបស់ពួកគេហើយបានទៅហែលទឹកប៉ុន្តែវាជាការដូច្នេះ។ពួកគេ មិនបានចាប់អារម្មណ៍ទេនោះ។ វាជាទំនៀមទម្លាប់ របស់ប្រទេសបារាំង។

38 នៅអាហ្វ្រិកស្ត្រីនិងបុរស ទាំងក្មេង និងចាស់ដើរគ្មានសម្លៀកបំពាក់ អ្វីទាំង អស់ដើរលើវាលស្មៅធំនៅទីនោះ។ មិនដែលស្គាល់អ្វីជាបន្ទប់ទឹកនោះទេឬអ្វីផ្សេងទៀត មិនដែលឃើញអ្វីផ្សេងទៀតទេ។ ប៉ុន្តែពួកគេមិនដឹងពីភាពខុសគ្នាទេ។ ពួកគេមិនដឹងពីភាពខុសគ្នានោះទេ។ ប៉ុន្តែវាជាទំនៀមទំលាប់ របស់ប្រទេសជាតិ។

39 ប៉ុន្តែខ្ញុំបាននិយាយថា "អូនសំលាញ់យើងខុសគ្នា យើងមកពីសាសន៍ផ្សេងគ្នា។ យើងអ្នកដំណើរនិងជាអ្នកចម្លែកនៅទីនេះ ដែលធ្វើឲ្យយើងមើលទៅខុសគ្នាដូច្នេះ។ ត្បិតព្រះគម្ពីរបានចែងថា 'ពួកគេបានប្រកាសអះអាងថា ពួកគេបានបង្ហាញថាពួកគេជាអ្នកដំណើរនិងជាមនុស្សចម្លែក ពួកគេកំពុងស្វែងរកទីក្រុងមួយដើម្បីមក។'"

40 បុរសឬស្ត្រីនៅក្នុងប្រទេសអ៊ីតាលី នៅបារាំង នៅអាហ្វ្រិក និងនៅប្រជាជាតិណាផ្សេងទៀត មិន បានកើតជាថ្មីដោយព្រះវិញ្ញាណបរិសុទ្ធទេចូរកុំធ្វើដូច្នោះ។ ពួកគេមិនស្លៀកសំលៀកបំពាក់ទេ។ ពួកគេមិនធ្វើដូចនោះទេព្រោះពួកគេបានមកពី ប្រជាជាតិផ្សេង មួយដែលមានអ្នកគ្រប់គ្រងនិងជាអ្នកបង្កើតជាព្រះ។ យើងមកពីស្ថានសួគ៌។ វិញ្ញាណនៅក្នុងខ្លួនរបស់អ្នក លើកទឹកចិត្តដល់ជីវិតអ្នក។ ប្រសិនបើអ្នកជាជនជាតិអាមេរិចអ្នកនឹងធ្វើដូចអាមេរិកបានធ្វើ។ ប្រសិនបើអ្នកជាជនជាតិបារាំងអ្នកនឹងធ្វើដូចបារាំងបានធ្វើ ហើយបានរិះគន់ដល់ ប្រទេស មួយផ្សេងទៀត។ ប៉ុន្តែប្រសិនបើអ្នកគឺជាកូនរបស់ព្រះអ្នកនឹងធ្វើអ្វីដូចអ្វីដែលនៅ ស្ថានសួគ៌វិញដ្បិតវិញ្ញាណរបស់អ្នកមកពីឋានខ្ពស់ហើយវានិងគ្រប់គ្រងអ្នក។

41 ការអ៊ីបន្តិចបន្តួចអ្នក ប្រហែលជាមើលទៅវា។ នៅក្នុងបទគម្ពីរអស់អ្នក ដែលស្វែងរកទីក្រុងថ្មីនេះបានប្រព្រឹត្តខុសពីមុន។ ពួកគេបានអះអាងថាពួកគេ ជាអ្នកដំណើរហើយចម្លែក។ ប៉ុន្តែនៅលើផ្នែកនៃជីវិតរបស់កាអ៊ីនគេបានក្លាយជាជនល្មើសនិងផ្តាច់ខ្លួន។ ប៉ុន្តែគ្រីស្ទានជាអ្នកដំណើរនិងចម្លែក។ ជនល្មើសគ្មានផ្ទះទេ។ អ្នកផ្តាច់ខ្លួនជាមនុស្សអាក្រក់។ ប៉ុន្តែអ្នកដំណើរគឺជាអ្វីមួយដែលពិតនិងមកពីទឹកដីពិតប្រាកដនៃសាសន៍ផ្សេង ព្យាយាមដើម្បីស្វែងរកផ្លូវទៅផ្ទះ ដោយបង្ហាញអត្តសញ្ញាណពីការរស់នៅរបស់គាត់នូវអ្វីមួយដែលគាត់មាន។ នេះជាហេតុផល។

42 ប៉ុន្តែមនុស្សដែលធ្វើដូច្នេះ មនុស្សដែលពាក់បែបនោះខ្ញុំសូមប្រាប់អ្នក។ នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងនៅពេលដែលខ្ញុំបានឃើញអ្នកមិនជឿសាមសិបពាន់នាក់ គ្មានសំលៀកបំពាក់ រុំភួយជាអ្នកស្រុកដើម។ ក្មេងស្រីដែលមានអាយុដប់ប្រាំមួយ ដប់ប្រាំបី ម្ភៃឆ្នាំ និងក្មេងប្រុសហើយគ្មានសម្លៀកបំពាក់ឈរនៅទីនោះ ភក់នៅពេញមុខនិងលាបលើមុខ ឆ្អឹងកាត់ច្រមុះ ហើយមានឈើព្យួរជាប់ត្រចៀករបស់ពួកគេ ដាក់ឆ្អឹងមនុស្សឬឆ្អឹងសត្វនៅលើសក់ ហើយធ្មេញសត្វព្យួរលើខ្លួនគេ។អាក្រាតដូចដែលពួកគេបានចូលមកក្នុងពិភពលោកដំបូង ដែលមិនបានដឹងអ្វីទាំងអស់។ ប៉ុន្តែនៅពេលដែលពួកគេបានទទួលព្រះគ្រីស្ទ ហើយមានអារម្មណ៍ថាបានទទួលព្រះវិញ្ញាណបរិសុទ្ធ ពួកគេ ក្រោកឡើង អោបដៃដើម្បីបាំងការអាម៉ាស់ដល់ទ្រូងរបស់ពួកគេ ហើយដើរទៅរក សម្លៀកបំពាក់ដើម្បីពាក់នៅលើខ្លួនរបស់ពួកគេ។ ហេតុអ្វី? ពួកគេបានក្លាយជាអ្នកដំណើរនិងចម្លែកនៅលើពិភពលោកវិញ។ ហាលេលូយ៉ា! ពួកគេនៅឆ្ងាយពីទ្រង់។ ហ្នឹងហើយ។

43 អូ មនុស្សទាំងនេះបានហៅខ្លួនឯងថាជាគ្រីស្ទាន។ ពួកគេជាកម្មសិទ្ធិរបស់ក្រុម ជំនុំមួយ។ ពួកគេបានចេញទៅហើយនិយាយថា "យើងជាពួកមេតូឌីស្ទ។ យើងជាពួកបាបទីស្ទ។ យើងជាពួកពេនទីកុស្ត (Pentecostals)។ យើងជាពួកសេវេនដេអេដវេនទីស្ទ។ យើងជាពួក *នេះ ពួកនោះ* ហើយ *ផ្សេងទៀត*។" នោះមិនមានណាមួយដែលត្រូវកាន់តាមនោះទេ។ វិញ្ញាណរបស់អ្នកជាជីវិតដែលនៅក្នុងអ្នកនោះជំរុញអ្នកនោះ និងប្រាប់ពីអ្វីដែលអ្នកនោះមាន។ ព្រះយេស៊ូវមានព្រះបន្ទូលថា "តាមរយៈផលផ្លែរបស់ពួកគេអ្នកនឹងបានស្គាល់ពួកគេ។"

44 ក្រុមជំនុំនេះបានក្លាយទៅដូចជាប្រជាជនអ៊ីស្រាអែលជាលើកដំបូង។ ពួកគេបានឃើញសាសន៍ដែលមិនជឿមានស្តេច។ ព្រះទ្រង់ជាស្តេចរបស់ពួកគេ។ ហើយ

ពួកគេបានមើលឃើញថាសាសន៍ដទៃនោះមានស្តេច ដូច្នេះពួកគេចង់ធ្វើដូចជាសាសន៍ដែលមិនជឿនោះដែរហើយពួកគេបានទិញស្តេចមួយសម្រាប់ខ្លួនឯង។ ហើយពេលពួកគេបានធ្វើវាពួកគេក៏ជួបបញ្ហា។ វាបានចាប់ផ្តើមចូលមកបន្តិចម្តងៗ។ លោកីយ៍បានចាប់ផ្តើមចូលទៅក្នុងខ្លួនពួកគេបន្តិចម្តងៗ។ ទីបំផុតបានបញ្ចប់ឡើងនៅក្នុងរាជស្តេចអ័រហាប់។ ស្តេចមួយអង្គបានខិតជិតបន្តិចម្តងៗទៅរកបញ្ហា បន្តិចម្តងៗខិតទៅជិតវាហើយទីបំផុតបានផ្តាច់ជីវិតចេញពីពួកគេ។ នៅទីនោះពួកគេនឹងបានទៅ។ ហើយពេលដែលស្តេចពិតប្រាកដមកពួកគេ មិនស្គាល់ទ្រង់ទេ។

45 នោះជារឿងដូចគ្នាក្នុងក្រុមជំនុំបានធ្វើ។ ពួកគេត្រូវបានប្រព្រឹត្តដូច្នោះ។ អ្នកគឺនៅទីនេះដែរ។ វាលជានយោបាយ ការអប់រំ។ ក្រុមជំនុំត្រូវបានប្រតិបត្តិតាមអង្គការ សង្គម ព្រះវិហារធំៗ គ្រូគង្វាលអំនួតៗ។ ហើយនៅពេលដែលស្តេចពិតប្រាកដមកពួកគេមិនស្គាល់ទ្រង់ទេ ហើយពួកគេឆ្កាងព្រះវិញ្ញាណបរិសុទ្ធដែលជាស្តេចរបស់ពួកគេ។ ពួកគេ មិនបានស្គាល់ទ្រង់ទេប៉ុន្តែពួកគេសើចចំអកដាក់ទ្រង់។ ដូចដែលពួកសាសន៍យូដាបានធ្វើចំពោះព្រះមេស្ស៊ីរបស់ពួកគេ ក្នុងក្រុមជំនុំក៏ បានធ្វើចំពោះព្រះមេស្ស៊ីដូចគ្នាដែរ។ពួកគេមិនបានដឹងនោះទេ។ ពួកគេមិនមាន ការយល់ដឹងខាងវិញ្ញាណនោះទេ ព្រោះពួកគេជឿលើឯកសារដែលពួកគេមើលឃើញ ហើយអ្វីដែលគេឃើញអាគារធំៗ ព្យាយាមប្រៀបធៀបជាមួយលោកីយ៍។ យើងមិនដែលបង្រៀន—បង្រៀនឲ្យប្រៀបធៀបជាមួយលោកីយ៍នោះទេ។ យើងបានបង្រៀនឱ្យបន្ទាបខ្លួនវិញ។

46 ហើយមួយទៀតសំខាន់បំផុតគឺនៅជាប់ជាមួយព្រះ។ ហើយនៅថ្ងៃនេះមានការព្យាបាលរបស់គ្រូគង្វាលម្នាក់នៅលើវាលស្មៅ មានដៃម្នាក់ចង់ធ្វើការប្រកួតប្រជែងជាមួយ។ ម្នាក់នោះនិយាយថា "សូមព្រះប្រទានពរព្រះជាម្ចាស់ ខ្ញុំមាន ច្រើនពាន់នាក់។ ខ្ញុំមានការប្រជុំដ៏ធំជាងអ្នក។" តើអ្វីដែលធ្វើឱ្យមានភាពខុសគ្នា? យើងមានម្នាក់ឬមួយលាននាក់អ្វីដែលធ្វើឱ្យមានភាពខុសគ្នា? តើយើងជឿ លើ ព្រះពិតទេ? តើយើងជឿលើព្រះបន្ទូលរបស់ព្រះទេ? តើយើងឈរនៅក្រោមការ សាកល្បងនៃព្រះវិញ្ញាណបរិសុទ្ធឬ? វាគឺជាការពិតឬ? នោះហើយគឺជារឿង សំខាន់។

47 ប៉ុន្តែយើងសម្របតាមព្រះគម្ពីរ។ មានក្រុមជំនុំពេនតេកុស្តជា ច្រើនដែលមានមូលដ្ឋានគ្រឹះនៅលើព្រះគម្ពីរ។ មាន...ខ្ញុំមិនចង់ឲ្យឈឺចាប់ផ្នែកអារម្មណ៍ទេ។ ខ្ញុំនៅក្នុងក្រុមជំនុំរបស់ខ្ញុំ ហើយខ្ញុំមានអារម្មណ៍ថាខ្ញុំ—ខ្ញុំចង់ធ្វើអ្វីតែនៅក្នុងក្រុមជំនុំរបស់ខ្ញុំប៉ុនោះ ព្រោះខ្ញុំកំពុងអធិប្បាយពីដំណឹងល្អ។ ប៉ុន្តែមានគ្រូអធិប្បាយពេនតេកុស្តរាប់ម៉ឺននាក់ដឹងថាគ្មានការនេះនៅក្នុងព្រះគម្ពីរដែលជ្រមុជទឹកក្នុងព្រះនាម "នៃព្រះវរបិតាព្រះរាជបុត្រានិងព្រះវិញ្ញាណបរិសុទ្ធ។" ខ្ញុំបានសាកល្បងជាមួយអាចារ្យ ឬនរណាម្នាក់ឲ្យបង្ហាញខ្ញុំ កន្លែងណា ដែលមនុស្សគ្រប់គ្នាបានទទួលបុណ្យ ជ្រមុជ ទឹកក្នុងព្រះនាមនៃ "ព្រះវរបិតាព្រះរាជបុត្រានិងព្រះវិញ្ញាណបរិសុទ្ធ។" ប៉ុន្តែ ពួកគេបានសម្របព្រោះក្នុងអង្គការទាំងមូលក៏ធ្វើដូច្នោះដែរ។ តាំងពីដើមគ្មានមនុស្សណាម្នាក់នៅក្នុងគម្ពីរសញ្ញាថ្មីនិងបីរយឆ្នាំក្រោយទៀតធ្វើបែបនោះទេប៉ុន្តែជ្រមុជក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ ចុះវាយ៉ាងម៉េច? គឺអង្គការ។ ដែលបានធ្វើវា។ សម្របតាមវា!

48 ហើយ សព្វថ្ងៃនេះពួកគេបានយកកម្មករតាម ផ្លូវទាំងអស់ចេញពីដង ផ្លូវ។ ពួកគេបានយកក្រាប់ចេញពីក្រុមជំនុំ។ ពួកគេបានយកសិរីរុងរឿងចេញពីក្រុមជំនុំនិងមាន ការអធិប្បាយនៅក្នុងសិក្ខាសាលា ជាការអធិប្បាយដែលគ្មានន័យសំរាប់ព្រះ ទាំងអស់គឺចាំងក្នុងសង្គមហើយស្រ្តីស្លៀកខោខ្លី និងរ៉ូបដែល កំពុង បញ្ចេញសាច់ហើយបុរសជក់បារី លេងល្បែង និងនិយាយរឿងអាសអាភាស។ វាជាភាពអាម៉ាស់នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់! ខ្ញុំដឹងថាជាការលំ បាកប៉ុន្តែវាជា ពេលដែលនរណាម្នាក់ត្រូវនិយាយអ្វីមួយ។ ការសម្របតាមកំពុងផ្តល់ឱ្យនៅក្នុងការប្រព្រឹត្តដូចលោកីយ៍!

49 ខ្ញុំមិនខ្វល់ថាខ្ញុំត្រូវឈរតែម្នាក់ឯងនឹងគ្មាននរណាម្នាក់នៅជាមួយ ប៉ុន្តែ ព្រះតែមួយគត់ដែលខ្ញុំនឹងផ្សាយសេចក្តីពិតនៃព្រះគម្ពីររបស់ព្រះហើយឈរលើជំនឿដ៏រឹងមាំ។ ប្រសិនបើខ្ញុំស្លាប់ខ្ញុំនឹងនៅតែឈរក្នុងសេចក្តីពិត។ ជាការពិតណាស់។ យើងចង់បានសេចក្តីពិត។ ខ្ញុំនឹងមិនរស់វាតាមរយៈព្រះវិហារផ្សេងៗនោះទេ ប៉ុន្តែគឺយោងតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលខ្ញុំចង់រស់។

50 ប៉ុន្តែដេលីឡា តើអ្នកបានសម្គាល់ទេ? នាងដឹងថាសាំសុនមានកំលាំង។ តែនាងមិនបានដឹងថាកំលាំងនោះទុកនៅកន្លែងណាឡើយ។ នាងមិនអាចប្រាប់នូវអ្វីដែលជាអំណាចនោះទេ ប៉ុន្តែមានកម្លាំងខ្លាំងមួយដែលសាំសុនបានកាន់កាប់

ហើយនាងចង់រកវាឱ្យឃើញ។ ហើយដូចដែលនាងដេលីឡាបានញ៉ៃញ៉ង់ សាំសុនដោយសម្រស់របស់នាង។ អូនាងបានស្លៀកពាក់បែបស្រើបស្រាល។ ហើយនាងបានដើរទៅមុខគាត់និងនាងបានធ្វើឬកដូចក្មេង ជំទង់ៗសព្វថ្ងៃ ជាដើមហើយ—ហើយគ្រាន់តែចង់ធ្វើអ្វីមួយដូចអ្នកផ្សេងទៀតនាងព្យាយាម ដើម្បីទាក់ទាញសាំសុន។

51 នោះជារឿងដដែលដែលលោកីយ៍បានធ្វើចំពោះក្រុមជំនុំ។ ឥឡូវនេះតើដ៏ខ្លាំងរបស់អ្នកនៅឯណា?

52 "អើ ប្រសិនបើយើងរៀបចំ នោះនឹងបំបែកកំលាំងនោះ។" ព្រះវិហារកាតូលិកបានធ្វើវាហើយ។

53 "ប៉ុន្តែភីលីស្ទីនមកចាប់អ្នកហើយ សាំសុន។" ហើយលោកលូធឺចេញមក។

54 បន្ទាប់មកពួកគេបានរៀបចំម្តងទៀត។ "ប្រសិនបើអ្នកនឹងចងខ្ញុំដោយ ខ្សែរមួយផ្សេងទៀតវានឹងជាប់។"ដូច្នេះពួកគេបានធ្វើ។

55 "ពួកភីលីស្ទីនមកហើយសាំសុន។" តើមានអ្វីកើតឡើង? លោកវេស្លីចេញមក និងបានបំបែកខ្សែនោះ។

56 "ឥឡូវនេះអ្នកបានបញ្ឆោតខ្ញុំជាយូរមកហើយ។ តើអ្នកមិនដឹងថាខ្ញុំស្រឡាញ់អ្នកទេសាំសុន? ត្រូវប្រាប់ខ្ញុំពីសេចក្តីពិតនៅក្នុងចិត្តរបស់អ្នក។"

"យល់ព្រមចូរអ្នកចងខ្ញុំដោយខ្សែមួយទៀត។"

57 "ត្រឹមត្រូវពេលនេះអ្នកនឹងធ្វើបាន។" តើវាជាអ្វី? នោះជាខ្សែនៃនិកាយ។

58 "ទ្រង់អនុញ្ញាតឱ្យខ្ញុំមានសេរីភាពខ្ញុំមិនត្រូវការទទួលនិកាយផ្សេងទេ។ បន្ទាប់មកខ្ញុំប្រាប់អ្នកចុះ អ្នកនឹងអាចបំបែកខ្ញុំបាន។" ដូច្នេះក៏មានអ្នកពេនទីកុស្តនិយម។ កន្លែងណាដែលជាអំណាចរបស់អ្នក?

"ពួកភីលីស្ទីន បានមកហើយ។" ហើយគាត់បានផ្តាច់ខ្សែម្តងទៀត។

59 ប៉ុន្តែឥឡូវនេះតើមានអ្វីកើតឡើង? មានអ្នកពេនទីកុស្ត ជាបណ្ឌិតខាងទេវវិទ្យាជាគ្រូគង្វាលរបស់ពួកគេ និងមនុស្សអស្ចារ្យផ្សេងទៀត។ ពួកគេមានគ្រាន់តែជាអ្វីដែលមាននៅសាលាហនិងក្នុងក្បួនសាសនាដែល មេតូឌីសឬបាបទីស្ទឬអ្នកផ្សេងទៀតក្នុងចំនោមពួកគេមានតែប៉ុនោះ។ ចូលទៅក្នុង ព្រះវិហារមួយហើយអ្នកមិនអាចស្តាប់ឮថា"អាម៉ែន" គ្រាន់តែជាមែកធាងមួយនៃ អីស្គីមូស(Eskimos)

ចេញពីខាងស្តាំនៃប៉ុលខាងជើង។ ត្រជាក់! គ្មានចំណាប់អារម្មណ៍!"ហើយឥឡូវភីលីស្ទីនមកចាប់អ្នកហើយសាំសុន។"

